

# ជុំ កាណាល់

(១៩៤៨-២០២១)[1]

ផ្គុំទិន្នន័យ

ដោយ

**បណ្ឌិតសភាចារ្យ ឃីងហុកឌី**

[1] *ជីវប្រវត្តិសង្ខេបខាងក្រោមនេះអ្នកនិពន្ធបានសរសេរផ្ទាល់ហើយបានប្រគល់មកខ្ញុំនាពេលខ្ញុំធ្វើកិច្ចសម្ភាសន៍ក្នុងការិយាល័យលោកនាឆ្នាំ១៩៩៥។*

# ប្រវត្តិសង្ខេបរបស់អ្នកនិពន្ធ

# ជុំ គារណាល់

លោក **ជុំ គារណាល់** កើតនៅថ្ងៃ ០២ ឧសភា ១៩៤៨ នៅភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ក្នុងត្រកូលគ្រួសារកសិករ។ ឪពុកឈ្មោះ **ទ្រាត់ ឈឿន** អាយុ៧៥ឆ្នាំ មុខរបរជាងកាត់សក់និងធ្វើស្មៀនឃុំសារិកាកែវ គាត់ឈប់ក្នុងឆ្នាំ ១៩៦៧ មកប្រកបរបរជាងកាត់សក់វិញ ។ ម្តាយលោកឈ្មោះ**សួន លាត** អាយុ៧៦ឆ្នាំ គាត់ស្លាប់ ក្នុងឆ្នាំ១៩៩៥ ខែមិថុនាដោយរោគចាស់ជរា។

លោក **ជុំ គារណាល់** កាលពីកុមារភាព លោកបានសិក្សានៅសាលាបឋមសិក្សាវត្តបន្ទាយ ហៅសុវណ្ណសាគរ ក្រោយមកផ្លាស់មកសិក្សានៅសាលាបឋមសិក្សាជ្រោយចង្វា ថ្នាក់ទី៧ ។ លោកបានប្រឡងចូលថ្នាក់ទី៦ទំនើប នៅវិទ្យាល័យព្រះស៊ីសុវត្ថិ កាលនោះគេយកថ្លៃបង់វិទ្យាល័យ៣.៥០០៛ ដោយជីវភាពគ្រួសារខ្វះខាតគ្មានលុយបង់ លោកក៏សម្រេចចិត្តមករៀននៅវិទ្យាល័យឯកជនតារាសាស្រ្ត ក្រោយមកតារារស្មី បន្ទាប់មកទៀតឧកញ៉ានូកន ។

នៅឆ្នាំ ១៩៦៨ លោកបានប្រឡងឌីប្លូមជាប់ នៅមណ្ឌលវិទ្យាល័យស៊ីសុវត្ថិ ក្នុងនិទ្ទេសល្អ ។ លោកមានបងប្អូន៦នាក់ សុទ្ធតែប្រុសទាំងអស់ ក្នុងនោះលោកជាកូនទីប្រាំ ។ ពេលមករៀននៅភ្នំពេញ លោកសំណាក់នៅវត្តលង្កា កុដិលេខ២៣៣ របស់ព្រះគ្រូធម្មបាលខៀវជុំ ។ លោកជាសិស្សជំនិតផ្ទាល់របស់ព្រះគ្រូធម្មបាលខៀវជុំ តាំងពីរៀបចំចង្ក្រាន់ កន្លែងសឹង ថ្នាំពេទ្យនិងទូដែកលុយ។ល។ មិនតែប៉ុណ្ណោះ លោកជាអ្នកជួយកែសៀវភៅនិពន្ធនានារបស់ព្រះគ្រូធម្មបាលខៀវជុំទៀតផង។

លោកបានប្រឡងចូលមហាវិទ្យាល័យសិល្បៈ មុខរបរឫស្សីកែវភ្នំពេញ ក្នុងឆ្នាំ១៩៦៩ ។ ឯកទេសរបស់លោក គឺគ្រឿងម៉ាស៊ីន ( MECANICIEN GÉNERAL )ប៉ុន្តែលោកមិនពេញចិត្តនូវមុខវិជ្ជានេះឡើយ លោកតែងតែសិក្សានៅសាលាឯកជនពីអក្សរសិល្ប៍ខ្មែរជាមួយលោកគ្រូសាស្រ្តាចារ្យ ម៉ោង ហាប់អាន,លោក លី ធាមតេង,លោក សែម សូរនិងលោក ថាច់ សែម។ ពីនោះទៀត លោកបានសិក្សាជាមួយព្រះគ្រូបណ្ឌិត ប៉ាង ខាត់ ព្រះភិក្ខុធម្មបាល ខៀវ ជុំ រៀងរាល់យប់ ពីម៉ោង ៧ ដល់ ៩យប់ ។ លោកយកចិត្តទុកដាក់បំផុតនូវវិជ្ជានិពន្ធខ្មែរ និងនយោបាយដែលព្រះគ្រូធម្មបាលខៀវ ជុំ បង្រៀនផ្ទាល់ ។

លោកស្នាក់នៅវត្តតាំងឆ្នាំ១៩៦០-១៩៧២ ។ លោកបានសរសេរសៀវភៅទស្សនៈមួយជាការដកពិសោធន៍ជាដំបូងក្នុងឆ្នាំ១៩៦៨ ចុងឆ្នាំ ឧបត្ថម្ភដោយព្រះគ្រូធម្មបាលខៀវ ជុំ ដែលមានចំណងជើងថា "*ជីវិតអណ្តែតតាមខ្យល់*" ។ ក្នុងសៀវភៅនោះ លោកបញ្ជាក់ពីជីវិតកូនអ្នកក្រ ដែលយកវត្ត

អារ៉ាមជាជម្រក យកព្រះសង្ឃជាអាណាព្យាបាល វាយតម្លៃការខំប្រឹងប្រែងតស៊ូរៀនសូត្ររបស់កូនអ្នកក្រ វាយតម្លៃកូនអ្នកមាន រៀនបានតិចតួច តែបានទៅរៀននៅបរទេសដោយសារប្រាក់សំណូកជាមូលដ្ឋាន ។ល។ សៀវភៅនេះបោះពុម្ពចំនួន ៣.៥០០ ច្បាប់ ត្រូវលក់អស់ ដែលជាការចាប់អារម្មណ៍ដល់យុវសិស្ស និស្សិតទាំងឡាយជាកូនអ្នកក្រ ។ នេះជាស្នាដៃដំបូងរបស់លោកដែលត្រូវបានទទួលជោគជ័យក្នុងការនិពន្ធរបស់លោក ។ ក្រោយមកលោកបានតែងនិពន្ធប្រលោមលោក២រឿងទៀត គឺដងស្ទឹងបាត្តនិងបុប្ផាអរិយក្សត្រ" ដែលជាប្រលោមលោកមនោសញ្ចេតនាជីវិតសោកនាដកម្ម ស្នេហាព្រាត់ប្រាស ប្រកាន់វណ្ណៈក្នុងវ័យសិក្សាដែលជារបាំងរនាំងក្នុងការសិក្សា។ គឺជាស្នាដៃក្នុងឆ្នាំ ១៩៦៩-១៩៧០ ។ ១៨មិនា១៩៧០ឡើងមក លោកបានដៃគូម្នាក់ជាមិត្តរបស់លោក គឺលោក ង៉ុយ សំភាហៅទី ជីហួត ដែលជាអ្នកនិពន្ធប្រលោមលោកគុណនិយម ។ ពីឆ្នាំ១៩៧០-៧៣ លោកជានិស្សិតផង ជាអ្នកនិពន្ធផង ព្រមទាំងជាអ្នកយកពត៍មានអោយកាសែតកោះសន្តិភាពរបស់លោកចាងហ្វាង ជូ ថានីផង ។ ប្រលោមលោកដែលជាស្នាដៃរបស់លោកមានរឿង "*ដងស្ទឹងស្រមោច*" ក្នុងខេត្តបាត់ដំបង, រឿង"*ដងស្ទឹងបាត្ត*" ,រឿង"*ផ្កាបីសរសៃ*" ,រឿង "*កូនអើយឥតម៉ែ*", រឿង"*ទឹកភ្នែកបុរសពោះម៉ាយ*", រឿង"*ជីវិតក្មេងកំព្រា*" និងសៀវភៅទស្សនៈ"*រស់កំដរស្លាប់*" ។ អត្ថបទទាំងនេះ លោកបានរៀបរាប់ពីសេចក្ដីស្នេហាថ្លៃថ្នូរ រវាងអ្នកក្រនិងអ្នកមាន រវាងបុរសទីក្រុងនិងក្រមុំជនបទ ពីការអប់រំទូន្មាន ។ល។

ចុងក្រោយនៃការនិពន្ធរបស់លោកសម័យនោះ គឺសៀវភៅទស្សនៈ រស់កំដរស្លាប់ ដែលជាទស្សនៈរបស់លោកផ្ទាល់បានលើកឡើងពីសង្គ្រាមវិនាសកម្ម ប្រជាពលរដ្ឋភៀសខ្លួនមកនៅទីក្រុងតាមសំយ៉ាបវត្តអារ៉ាម និងផ្ទះចិន ទំនិញឡើងថ្លៃ រដ្ឋាភិបាលឥតគិតគូរ រស់ដូចដរី បោលចូលក្ដិតម្ជុលពួកមានអំណាចជាទាហានចាប់ស្រី ៧លក់ បោកបញ្ឆោតស្រី១កូនអ្នកភៀសខ្លួន យកទៅលក់អោយជង្ហៅចោរ ។ល។

នេះជាចុងបញ្ចប់នៃការតែងនិពន្ធក្នុងជំនាន់ស្រុកសង្គ្រាម លោកត្រូវរដ្ឋាភិបាលយោធារបស់លោកលន់នល់តាមចាប់ខ្លួនលោក ។ លោកភៀសខ្លួនចេញពីទីក្រុងនៅចុងកាត់មាត់ញក ភូមិថ្មី ឃុំដង្កោ ស្រុកដង្កោ ខេត្តកណ្ដាល កាប់អុសសង្កែលក់ ហើយផ្លាស់ឈ្មោះ ។

លោកឌុំ **ភារណារ៉ាល់**បញ្ចប់ការសិក្សានៅមហាវិទ្យាល័យសិល្បៈមុខរបរ មានសញ្ញាប័ត្រ B.S. T និងជានិស្សិតវិស្វករខាងបច្ចេកទេសផ្នែកម៉ាស៊ីនឆ្នាំទី២ ។ ឈ្មោះ **ឌុំ ភារណារ៉ាល់** របស់លោកគឺជាការដាក់ដោយព្រះគ្រូធម្មបាលខៀវជុំ ។ ឈ្មោះរបស់លោក គឺជាការស្រឡាញ់របស់ព្រះគ្រូធម្មបាលខៀវ ជុំ ព្រោះព្រះអង្គបានចាត់ទុកលោកថា ជាសិស្សជំនិតដ៏ល្អរបស់លោក ហើយក៏អាចក្លាយជាអ្នកនិពន្ធ និងអ្នកនយោបាយមួយសំខាន់ៗពេលខាងមុខ ។

១៩៧៥-៧៩ លោកនឹងគ្រួសារលោកត្រូវពួកប៉ុលពត ជម្លៀសទៅនៅភូមិស្រមោច ស្រុកព្រះ

នេត្រព្រះ ខេត្តបាត់ដំបង ហើយនៅឆ្នាំ១៩៧៧ ចុងឆ្នាំ១៩៧៨ លោកត្រូវពួកនោះចាប់ដាក់គុកនៅជប់ព្រះនេត្រព្រះ ហើយបញ្ជូនទៅភ្នំកូនខ្លែង ជាសមរភូមិអ្នកទោស ។ ពួកគេចោទប្រកាន់លោកជាបញ្ញាវ័ន្ត ហើយប្រុងបបួលលោករត់ចេញទៅប្រទេសទី៣ ។ លោកត្រូវប៉ុលពតសម្លាប់បងប្រុសម្នាក់ជា Master មកពីរៀនប្រទេសកាណាដា មុនឆ្នាំ៧៥ លោកក៏ត្រូវស្លាប់កូនប្រុសម្នាក់អាយុ៣ឆ្នាំដោយជម្ងឺឥតថ្នាំព្យាបាល ។

១៩៧៩ ៧មករា ថ្ងៃរំដោះប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសចេញពីរបបប៉ុលពត លោកជាកងសេនាជនម្នាក់ប្រចាំភូមិ ការពារប្រជាពលរដ្ឋ ។ ចុងឆ្នាំ១៩៧៩ ដោយសកម្មភាពដ៏ល្អសកម្មរបស់លោក ត្រូវរដ្ឋអំណាចចាត់តាំងលោកឱ្យទៅជាប្រធានចាត់តាំងស្រុកដង្កោក្នុងខេត្តកណ្ដាល ពេលនោះ (សព្វថ្ងៃស្រុកដង្កោ នៅក្នុងរាជធានីភ្នំពេញ ) ។

ឆ្នាំ១៩៨០-៨៣ លោកត្រូវគេចាត់តាំងឱ្យទៅជាអភិបាលស្រុកដង្កោ ក្នុងរយៈពេល១០ឆ្នាំ លោកត្រូវបានមន្ត្រីនិងប្រជាពលរដ្ឋស្រឡាញ់ ដោយការដឹកនាំឈ្លាសវៃរបស់លោក។ លោកមិនដែលប៉ះពាល់អំពើពុករលួយឡើយ ។ លោកមានលំនៅស្ថានក្នុងស្រុកស្រែ ប្រពន្ធរបស់លោកធ្វើស្រែចិញ្ចឹមគ្រួសារ ហើយបានចិញ្ចឹមក្មេងកំព្រា១៨នាក់ ដែលពួកគេស្លាប់ម៉ែឪក្នុងជំនាន់ប៉ុលពត ។ លោកចិញ្ចឹមក្មេងទាំងនោះអោយរៀនសូត្រចេះដឹងដល់ឌីប្លូមនិងBaccII ព្រមទាំងមានបញ្ជូនទៅរៀននៅសូវៀត ពីនោះ អោយក្មេងទាំងនោះចូលធ្វើទាហានជើងគោក ជើងអាកាសនិងជើងទឹក ព្រមទាំងចូល Policeនិងអ្នកបច្ចេកទេសគមនាគមន៍ទៀតផង ។ ក្មេងទាំងនោះត្រូវលោករៀបការអោយមានគូរស្រករ សព្វថ្ងៃពួកគេមានកូនធំៗអស់ហើយ។ ទោះជាការងារមមាញឹកយ៉ាងណាក៏ដោយ ក៏លោកមិនចោលការនិពន្ធរបស់លោកដែរ ។ ពេលយប់ លោកតែងតែសរសេរសៀវភៅ តែងចម្រៀងសរ-សេរកាសែត និងកំណាព្យ ។ ស្នាដៃរបស់លោកមានរឿង" *ប្រាំឆ្នាំចាំបង* " , " *ទឹកខេត្តពោធិសាត់* " បោះពុម្ពផ្សាយក្នុងឆ្នាំ១៩៨៩-៩០ ។ ឆ្នាំ១៩៨៣ លោកត្រូវរដ្ឋាភិបាលផ្លាស់មកកាន់ជានាយករងមន្ទីរវប្បធម៌រាជធានីភ្នំពេញ ។ លោកបានតែងរឿងបីជាខ្សែ Video គឺរឿង " *ឃ្លាតទាំងទឹកភ្នែក* " , " *ថ្ងៃណាអូនវិលវិញ* " រឿង" *ព្យុះចិត្តភក្ដីស្រីកូនក្មេង* " ។ រឿងពីរដែលនិពន្ធផង ដឹកនាំរឿងដោយខ្លួនលោកផ្ទាល់ផងក្នុងផលិតកម្ម *ហង្សមាសភាពយន្ត* របស់លោកជាចាងហ្វាងឯរឿង" *ព្យុះចិត្តភក្ដី ស្រីកូនក្មេង* " ជាស្នាដៃនិពន្ធរបស់លោកអោយទៅជាផលិតកម្ម *កណ្ដឹងសាមពាន់ភាពយន្ត* ។

ពីនោះទៀត លោកបានតែងចម្រៀងក្នុងខ្សែVideo៩បទ និង៦៤បទទៀតអោយក្រុមហ៊ុននៅ U.S.A ថតចេញជាស៊ីឌី ថាសនិងCasette លក់ ។ ចម្រៀងទាំងនោះគឺជាចម្រៀងមនោសញ្ចេតនា ។

ឆ្នាំ ១៩៩៥ លោកត្រូវគេផ្លាស់អោយមកកាន់នាយករងមន្ទីរពត៌មានរាជធានីភ្នំពេញ ពេលនោះ លោកបានក្លាយទៅជាអ្នកនិពន្ធវិតតែល្បីថែមទៀត ។ លោកបានក្លាយទៅជាអ្នកនិពន្ធវិចារណ-កថានយោបាយអោយកាសែត" កោះសន្តិភាព "ដែលមាន ២០០ អត្ថបទ នយោបាយនិងកាសែតដទៃ

ទៀត ។ ក្នុងឆ្នាំនោះផងដែរ លោកបោះឆ្នោតជាប់ជាអនុប្រធានទី១ សមាគមអ្នកនិពន្ធខ្មែរ ហើយក៏ក្លាយទៅជាចាងហ្វាងនយោបាយកាសែតកោះសន្តិភាព ។ ឆ្នាំ១៩៩៥ លោកបានក្លាយជាប្រធានសម្ព័ន្ធអ្នកសារពត៌មានកម្ពុជា ដែលមានអង្គការសារពត៌មាន ៥២អង្គភាពមកដល់សព្វថ្ងៃនេះ ដែលជាអង្គការសារពត៌មានមួយក្រៅរាជរដ្ឋាភិបាល ធំជាងគេនៅក្នុងប្រទេសកម្ពុជា។ ដើម្បីឯករាជ្យ អព្យាក្រិត្យក្នុងវិជ្ជាជីវៈ សារពត៌មានលោកបានលាលែងពីនាយករងមន្ទីរពត៌មានរាជធានីភ្នំពេញ និងលាលែងពីចាងហ្វាងនយោបាយកាសែតកោះសន្តិភាព ។ សព្វថ្ងៃ លោកនៅសល់តួនាទីពីរ គឺប្រធានសម្ព័ន្ធអ្នកសារពត៌មានកម្ពុជានិងអនុប្រធានទី១សមាគមអ្នកនិពន្ធខ្មែរ ។ ទោះការងារមមាញឹកយ៉ាងណាក៏ដោយ ក៏លោកនៅតែខំនិពន្ធសៀវភៅ ខ្សែ Video រឿង" *មេកន្ទ្រាញភ្នំ១០០*", "*សំបុកឥតមេ* ", ស្រាវជ្រាវអារ្យធម៌ខ្មែរដោយសង្ខេប តែមិនទាន់បានថត និងមិនទាន់បោះពុម្ពផ្សាយនៅឡើយ។ ព្រមទាំងចម្រៀង៧បទក្នុងរឿងទាំង២នេះផង ។ ក្នុងឆ្នាំ១៩៩៦នេះលោកបានតែងសៀវភៅ" *អក្សរសិល្ប៍ខ្មែរបែបទំនើបដោយសង្ខេប*" ,និងរឿង" *ខុសបំណង*" ដែលបានបោះពុម្ពផ្សាយរួចហើយ។ ឯសៀវភៅប្រលោមលោកមួយទៀត រឿង" *ជីវិតទឹកភ្នែក*" គឺមិនទាន់បោះពុម្ពផ្សាយនៅឡើយ ។ សព្វថ្ងៃ លោកនៅតែមិនចោលសោះឡើយនូវការតែងនិពន្ធរបស់លោក ។ លោកកំពុងអនុវត្តន៍ការសរសេរអត្ថបទវិចារណកថានយោបាយអោយកាសែតនានាក្នុងសម្ព័ន្ធអ្នកសារពត៌មានកម្ពុជារបស់លោក ។ ពីនោះទៀត លោកសម្ភាសន៍តាមទូរទស្សន៍វិទ្យុ និងបង្រៀនដល់និស្សិតសកលវិទ្យាល័យពីវិជ្ជាជីវៈសារពត៌មានថែមទៀត ។ ក្នុងជីវិតរបស់លោកមានពេលទំនេរតិចណាស់ ព្រោះលោកប្រើខួរក្បាលយកស្លាបប៉ាកកាជាអាវុធ ប្រយុទ្ធលើសមរភូមិក្រដាសសអោយក្លាយទៅជាអត្ថបទនានា បំរើសមរភូមិសតិអារម្មណ៍យ៉ាងសំខាន់បំផុត ។

នេះជាប្រវត្តិសង្ខេបរបស់លោកអ្នកនិពន្ធ **ជុំ កាណាល់** ដ៏ល្បីម្នាក់ ។

++++++++ ++++++++ ++++++++

++++++++

*លោកជុំកាណាល់បានទទួលអនិច្ចកម្មនាឆ្នាំ២០២១ដោយជរាពាធ។*

# សារលិខិតចូលរួមរំលែកទុក្ខ

យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងសមាជិក

## សមាគមអ្នកនិពន្ធខ្មែរ

សូមចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំបំផុត ចំពោះមរណភាពរបស់
អ្នកនិពន្ធ ជុំ គាណាល់ អតីតអនុប្រធានសមាគមអ្នកនិពន្ធខ្មែរ(១៩៩៥-៩៧)
ដែលបានធ្វើកាលមរណៈនៅវេលាម៉ោង ៧.០០នាទី ថ្ងៃអាទិត្យ ៩រោច ខែផល្គុន
ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៧ ខែមីនា ឆ្នាំ២០២១ ក្នុងជន្មាយុ ៧០ ឆ្នាំ
ដោយជរាពាធ នៅគេហដ្ឋានសព ភូមិម័រ ខណ្ឌដង្កោ រាជធានីភ្នំពេញ។



សូមឲ្យដួងវិញ្ញាណក្ខន្ធលោកគ្រូ ជុំ គាណាល់ ទៅកាន់
ឋានសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

# ឧបសម្ពន្ធ





បោះពុម្ពផ្សាយ
ដោយមន្ទីរឃោសនាការ
វប្បធម៌រដ្ឋធានី


ទឹកចិត្ត


ជុំ-កាណភាល់
វណ្ណកម្មសំរាប់ថ្ងៃសៅរ៍
រឿង
ខុសបំណាង
ប្រលោមលោក មនោសញ្ចេតនាជីវិតសោក
រក្សាសិទ្ធិ